**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៧០ **អយក.**សលន

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីណែនាំស្តីពី
# ការប្រមូល និងបំពេញតារាងជំរឿនស្ថិតិសាលារៀនសាធារណៈសម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨

ក្នុងគោលបំណងធ្វើឱ្យមានភាពសុក្រឹតក្នុងការប្រមូលទិន្នន័យអប់រំគ្រប់ប្រភេទពីសាលារៀនសាធារណៈ គ្រប់ភូមិសិក្សា ទូទាំងប្រទេសសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោមៈ

**១-គ្រូបង្រៀនទទួលបន្ទុកថ្នាក់**

ត្រូវបំពេញតួលេខស្ថិតិសិស្សជាក់ស្តែងនៅក្នុងថ្នាក់រៀននិមួយៗទៅក្នុង " តារាងសម្រាប់គ្រូ " (ដូចមានជូនភ្ជាប់) ឱ្យបានពិតប្រាកដ និងគ្រប់គ្រាន់ រួចត្រូវបញ្ជូនទៅទីចាត់ការសាលារៀនឱ្យបានមុនថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីឱ្យលោកនាយក លោកស្រីនាយិកាសាលារៀនធ្វើការបូកសរុបស្ថិតិសាលារៀនទាំងមូលក្នុងដំណាក់កាលបវេសនកាលដើមឆ្នាំសិក្សា។

**២-នាយក នាយិកាសាលារៀនទាំងអស់**

ត្រូវថតចម្លង "តារាងចំនួនសិស្សតាមថ្នាក់(សម្រាប់គ្រូ)" ឱ្យបានគ្រប់គ្រូបន្ទុកថ្នាក់ទាំងអស់។ បន្ទាប់មកលោកនាយក នាយិកាប្រមូលយកស្ថិតិសិស្សដែលគ្រូទទួលបន្ទុកថ្នាក់បានបំពេញមកបូកសរុបហើយកត់ត្រាចូលក្នុងចំណុចទី២.(ក) ទី២.(ខ) ទី២.(គ) និងទី៣ នៃតារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំ(ដូចមានជូនភ្ជាប់)។ ស្ថិតិសិស្សក្នុងតារាងទី២.(ក) ជាស្ថិតិបវេសនកាលឆ្នាំសិក្សា២០១៧-២០១៨ របស់សាលារៀន។ លោកនាយក លោកស្រីនាយិកាសាលារៀន ត្រូវបំពេញទិន្នន័យព័ត៌មានឱ្យបានសព្វគ្រប់ទាំងអស់ និងត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវទើបផ្ញើទៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ឱ្យបានមុនថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។ លោកនាយក លោកស្រីនាយិកាសាលារៀនត្រូវកត់ត្រាស្ថិតិបវេសនកាលនេះលើក្តារខៀនស្ថិតិនៅក្នុងទីចាត់ការ ដើម្បីប្រើប្រាស់ជាទូទៅឱ្យបានឯកភាពគ្នា។ ម្យ៉ាងវិញទៀតលោកនាយក លោកស្រីនាយិកាសាលារៀន ត្រូវប្រើប្រាស់ស្ថិតិសិស្សសរុបក្នុងតារាងទី២.(ក) សម្រាប់ការបំពេញរបាយការណ៍ដើមឆ្នាំសិក្សា ឬបវេសនកាល និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ឱ្យបានមុនថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។

### ៣-ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ

មានភារកិច្ចក្នុងការចុះសម្របសម្រួលការងារបំពេញតារាងជំរឿនស្ថិតិសាលារៀននៅតាមគ្រប់ភូមិសិក្សា និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងតារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ។ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតារាងប្រមូលទិន្នន័យ ប្រចាំឆ្នាំរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ (ដូចមានជូនភ្ជាប់) រួចផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបូកសរុបស្ថិតិ ដែលទទួលបានពីសាលារៀនដើម្បីរៀបចំរបាយការណ៍បវេសនកាលដើមឆ្នាំសិក្សា២០១៧-២០១៨ និងផ្ញើជូនទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រឹមថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

### ៤-មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត

ត្រូវផ្ញើជាបន្តបន្ទាប់នូវតារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំ និងតារាងប្រមូលទិន្នន័យប្រចាំឆ្នាំរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានប្រមូល និងបានផ្ទៀងផ្ទាត់ត្រឹមត្រូវ (ដោយមិនត្រូវពន្យាពេលរង់ចាំឱ្យបានគ្រប់សាលារៀន និងក្រុង ស្រុក ខណ្ឌ) ព្រមទាំងតារាងប្រមូលទិន្នន័យប្រចាំឆ្នាំរបស់ថ្នាក់រាជធានី ខេត្ត ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ) យ៉ាងយឺតបំផុតត្រឹម ថ្ងៃទី០៩ខែធ្នូ ឆ្នាំ២០១៧។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបញ្ចូល និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យឱ្យត្រឹមត្រូវគ្រប់ចំណុចនិងគ្រប់សាលារៀន រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ) ត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវរៀបចំជារបាយការណ៍បវេសនកាលដើមឆ្នាំសិក្សា២០១៧-២០១៨ របស់រាជធានី ខេត្ត ហើយបញ្ជូនទៅ ក្រសួងអប់រំយុវជន និងកីឡា (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ) ត្រឹមថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និង កីឡារាជធានីខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងនាយកសាលារៀន នឹងខិតខំពង្រឹងយន្តការនៃការបំពេញ និងប្រមូលតារាងជំរឿនស្ថិតិសាលារៀនសាធារណៈ ប្រចាំឆ្នាំសិក្សា២០១៧-២០១៨ នេះ បានពិតប្រាកដ គ្រប់គ្រាន់ និងទាន់ពេលវេលា ជាក់ជាមិនខាន។

សូមលោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ណាត ប៊ុនរឿន

**ចម្លងជូន:**

- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- អគ្គនាយកដ្ឋានអប់រំ
- អង្គភាព និងនាយកដ្ឋានពាក់ព័ន្ធ

  "ដើម្បីជូនជ្រាបជាព័ត៌មាន និងជួយសហការ"

- ឯកសារ-កាលប្បវត្តិ-នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ